**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខៈ ០៣៧ /០៧ កណ អ.គ.គ**

**កំណត់ហេតុ**

**ស្តីពី**

**សិក្ខាសាលាផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ**
**កំណែទម្រង់ច្បាប់ និងតុលាការនៅខេត្តមណ្ឌលគិរី**

ឆ្នាំពីរពាន់ប្រាំពីរ ខែ វិច្ឆិកា ថ្ងៃទី ដប់ប្រាំ វេលាម៉ោងប្រាំបី នៅសាលប្រជុំទីរួមខេត្តមណ្ឌលគិរី មានរៀបចំសិក្ខា សាលាមួយ ក្រោមអធិបតីភាពឯកឧត្តម **សួង លាងហៃ** ទីប្រឹក្សាទីស្តីការគណៈរដ្ឋមន្ត្រី និងជានាយករងអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីផ្សព្វផ្សាយកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលគណៈរដ្ឋមន្ត្រីបានអនុម័តកាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥។ ចូលរួមជាគណៈធិបតីក្នុងឱកាសនោះមាន ឯកឧត្តម **ឡាយ សុខា** អភិបាលខេត្តមណ្ឌលគីរី។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមអង្គសិក្ខាសាលា ឯកឧត្តម **ឡាយ សុខា** អភិបាលខេត្តមណ្ឌលគីរី បានសម្តែងកិច្ចស្វាគមន៍ ចំពោះគណៈអធិបតី គណៈប្រតិភូនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៅតាមមន្ទីរជំនាញផ្សេងៗជុំវិញមណ្ឌលគីរី ដែលមានវត្តមាននៅក្នុងអង្គសិក្ខាសាលាព្រមទាំងថ្លែងអំណរគុណដល់អង្គភាពគ្រប់ គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងធ្វើបទបង្ហាញជូនដល់មន្ត្រីរាជការនៃអង្គភាព ជំនាញផ្សេងៗរបស់ខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀត អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានបញ្ជាក់ថា អង្គសិក្ខាសាលានាពេលព្រឹកនេះ គឺត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ផ្សេងៗនៃការកែទម្រង់ច្បាប់ និងតុលាការជូនមន្ត្រីរាជការក្នុងខេត្ត ក្នុងខណៈដែលរាជរដ្ឋាភិបាលកំពុងតែធ្វើដំណើរឆ្ពោះទៅមុខ ប្រកបដោយឆន្ទៈដ៏មោះមុតជាមួយនឹងកម្មវិធីនយោបាយកំណែទម្រង់រដ្ឋ ដែលជាសមាសធាតុគន្លឹះ នៃអភិបាលកិច្ចល្អស្ថិតនៅ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលអាណត្តិទី៣នៃរដ្ឋសភា។

ជាបន្ទាប់ ឯកឧត្តម **សួង លាងហៃ** បានធ្វើបទអន្តរាគមន៍ ជម្រាបជូនអង្គសិក្ខាសាលាអំពី យុទ្ធសាស្រ្តចតុកោណ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិទីបីនៃរដ្ឋសភា ដែលមានកំណែទម្រង់បួន ជាស្នូលគឺកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់កងទ័ព កំណែទម្រង់ច្បាប់ និងតុលាការ និង ការប្រឆាំងអំពើពុករលួយ សម្រាប់លើកកំពស់អភិបាលកិច្ចល្អ ដែលជាគន្លឹះនៃការអភិវឌ្ឍន៍ប្រទេសជាតិ ឱ្យសំបូររុងរឿង។

ជាបន្តឯកឧត្តមបានជម្រាបជូនអង្គសិក្ខាសាលាទាំងមូលអំពីដំណើរការ នៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានចាប់ផ្តើមឡើងតាំងពីឆ្នាំ ២០០០។ ចាប់ពីពេលនោះមកក្រុមការងារមួយ ត្រូវបានបង្កើតឡើងជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិលើវិស័យច្បាប់ និងតុលាការ ហើយនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៣ យុទ្ធសាស្រ្តនៃកំណែទម្រង់ច្បាប់ និងតុលាការមួយត្រូវបានអនុម័តដោយ រាជរដ្ឋាភិបាលជាបន្ទាប់នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាល បានអនុម័តនូវកម្មវិធី សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការ ដែលរៀបចំឡើងលើមូលដ្ឋាន នៃឯកសារចក្ខុវិស័យ និងយុទ្ធសាស្រ្តឆ្នាំ ២០០៣។

កម្មវិធីសកម្មភាពនេះចែកចេញជាបីផ្នែក ៖

- សកម្មភាពរយៈពេលខ្លី
- សកម្មភាពរយៈពេលមធ្យម និង
- សកម្មភាពរយៈពេលវែង។

បន្ទាប់ពីបទបង្ហាញរបស់ឯកឧត្តមនាយករងអង្គភាពគ្រប់គ្រងគម្រោងមក លោក **លូ ស៊ូសម្បត្តិ** ប្រធានតុលាការខេត្តមណ្ឌលគីរី បានមានប្រសាសន៍លើកឡើងអំពីវិស័យច្បាប់ និងតុលាការក្នុង ខេត្តមណ្ឌលគីរីនេះ ដោយលោកប្រធានតុលាការបានជម្រាបជូនអង្គសិក្ខាសាលា អំពីស្ថានភាព របស់សាលាដំបូងខេត្តមណ្ឌលគីរីនាពេលបច្ចុប្បន្ន ដែលតែងតែជួបប្រទះក៏ដូចជា អំពីបញ្ហាប្រឈមមុខ ផ្សេងៗដូចជា ៖

- បញ្ហាខ្វះខាតថៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ដែលជាហេតុធ្វើឱ្យមានការកកស្ទះ សំណុំរឿងដែលដោះស្រាយមិនទាន់ពេល
- ខ្វះបន្ទប់សវនាការ
- ចំពោះបញ្ហាសាលាជម្រះក្តីវិញមានសភាពតូចចង្អៀត ហើយលោកបានជម្រាបអង្គ សិក្ខាសាលាថា ចំពោះសាលាដំបូងខេត្តមណ្ឌលគីរីបច្ចុប្បន្ននេះធ្វើការនៅក្រោមផ្ទះ ដោយ មិនសមស្របទៅនឹងការងារយុត្តាធិការ នៃស្ថាប័នច្បាប់ឡើយ។ ចំពោះសំណុំរឿងក្នុងឆ្នាំ ២០០៧ នេះមាន ៖
    - សំណុំរឿងរដ្ឋប្បវេណីមានចំនួន ៣៩ សំណុំរឿង
    - សំណុំរឿងព្រហ្មទណ្ឌមានចំនួន ៣៣ សំណុំរឿង
    - ចំពោះពិរុទ្ធជនជាប់ឃុំឃាំងក្នុងពន្ធនាគារមានចំនួន ៥១ នាក់
    - ចំពោះទណ្ឌិតជាប់ឃុំឃាំងក្នុងពន្ធនាគារមានចំនួន ៨នាក់

- ចំពោះការងារទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធ មានមន្ត្រីនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថមានភាព រលូនទៅមុខហើយ។

ឯកឧត្តម **ម៉ែន ម៉ុនឈា** នាយករងអង្គភាពគ្រប់គ្រងគម្រោងបានធ្វើការបង្ហាញ ពីដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការ។ ឯកឧត្តមបានលើកឡើងពីរចនាសម្ព័ន្ធ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ (ក.ក.ច.ន.យ) ដែលបានបង្កើតឡើង នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម **ឌិត មុន្ទី** ប្រធានតុលាការកំពូល សហប្រធាន(ក.ក.ច.ន.យ) បន្ទាប់មក ឯកឧត្តមបានជម្រាបជូនអង្គប្រជុំអំពីអង្គភាពនៅក្រោមឱវាទរបស់ក្រុមប្រឹក្សា ៖

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍(អ.ស.ស) ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌។
- អង្គភាពគ្រប់គ្រងគម្រោង(អ.គ.គ)ដែលបានបង្កើតឡើងនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ។

ជាបន្ទាប់ឯកឧត្តមបានធ្វើការបង្ហាញអំពីកម្មវិធីសកម្មភាព ដែលមានក្នុងឯកសារ សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ដែលមានចែកជូនជាឯកសារស្រាប់ដល់អង្គសិក្ខាសាលានាពេលនោះ ព្រមទាំងធ្វើការពន្យល់ផែនការសកម្មភាពនីមួយៗ និងបានដកស្រង់យកចំណុចសំខាន់ៗខ្លះ នៃឯកសារមកធ្វើអត្ថាធិប្បាយជូនអង្គសិក្ខាសាលា ដូចជា បញ្ហាប្រឈមមុខដែលត្រូវដោះស្រាយជាបន្ទាន់មានចែងក្នុងកម្មវិធីសកម្មភាពដូចជា បញ្ហាទប់ស្កាត់អំពើពុករលួយក្នុងតុលាការ និងការកកស្ទះសំណុំរឿងនៅក្នុងតុលាការ ដែលជាលទ្ធផលឧទាហរណ៍ដូចជានៅតុលាការក្រុងភ្នំពេញ បានដោះស្រាយរួចជាស្ថាពរនោះមាន ៖

- បញ្ហាខ្វះបន្ទប់សវនាការ
- បញ្ហាខ្វះមេធាវី
- បញ្ហាដឹកជញ្ជូនជនជាប់ចោទពីពន្ធនាគារចូលសវនាការ
- ការបង្វិលដីកាកោះជាដើម។ល។

ចំណែកបញ្ហាផ្សេងៗទៀត ដែលអង្គប្រជុំក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌បានសម្រេចមានដូចជា ៖

**១-កង្វះខាតចៅក្រម និងព្រះរាជអាជ្ញា** ៖ ជ្រើសរើសសិស្សចៅក្រមក្នុងមួយឆ្នាំអោយបានច្រើនជាអតិបរមាតាមលទ្ធភាពសាលាភូមិន្ទចៅក្រមអាចធ្វើទៅបាន។ ចំពោះគ្រូបង្រៀនសិស្សចៅក្រមនេះមិនចាំបាច់គិតពីគោលការណ៍ថា ទាល់តែជាចៅក្រមទើបអាចជាគ្រូបង្រៀនបាននោះទេ ត្រូវរកសាស្ត្រាចារ្យជំនាញបង្រៀនទ្រឹស្តី រួចយកចៅក្រមក្នុងការងារជាអ្នកអនុវត្តមកបង្រៀនបន្ថែម ព្រមទាំងគួរមានគ្រូបង្រៀនប្រចាំសាលាភូមិន្ទចៅក្រមផងដែរ។

**២-ការបណ្តុះបណ្តាលចៅក្រមសម្រាប់ទំនាស់ពាណិជ្ជកម្ម ៖**

ជាបឋមជ្រើសរើសចៅក្រម១២នាក់ពីចៅក្រមវិជ្ជា ជីវៈសព្វថ្ងៃ ។

**៣-ការបណ្តុះបណ្តាលក្រឡាបញ្ជី៖**

ស្នើអោយក្រសួងយុត្តិធម៌ ជ្រើសរើសក្រឡាបញ្ជីមកធ្វើការបណ្តុះបណ្តាល ហើយត្រូវគិតពីគុណភាពជាធំ។

**៤-ការបណ្តុះបណ្តាលអាជ្ញាសាលា៖**

ត្រូវរៀបចំក្របខណ្ឌច្បាប់មួយជាព្រះរាជក្រឹត្យ ឬអនុក្រឹត្យសិន ដើម្បីធ្វើការជ្រើសរើសអាជ្ញាសាលា មកធ្វើការបណ្តុះបណ្តាលសម្រាប់រយៈពេលពី ៦ខែ ទៅ ១ឆ្នាំ និងអោយរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ សហការជាមួយក្រសួងយុត្តិធម៌រៀបចំច្បាប់ជាមូលដ្ឋានបណ្តើរៗ។

**៥-លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា៖**

ត្រូវជម្រុញលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាចេញឱ្យបានឆាប់។

**៦-ការបោះពុម្ពសេចក្តីសម្រេចតុលាការ៖**

ស្នើអោយរកការឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើការសិក្សាលើសេចក្តីសម្រេចរបស់តុលាការទាញជាយុត្តិសាស្ត្រ និងស្វាគមន៍ចំពោះការសម្រេចចិត្តរបស់ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលយកសាលក្រមស្ថាពរនៃតុលាការខេត្ត ក្រុងទៅបោះពុម្ពផ្សាយដោយខ្លួនឯងវិញ។

**៧-តុលាការគំរូ៖**

ជម្រុញការអនុវត្តគម្រោងតុលាការគំរូ ព្រមទាំងដកស្រង់បទពិសោធន៍ល្អៗ និងចំណុចសំខាន់ៗនៃអង្គប្រជុំនុំជំរះវិសាមញ្ញកាត់ក្តីខ្មែរក្រហម ដែលមានលក្ខណៈស្តង់ដារអន្តរជាតិមកដាក់បញ្ចូលធ្វើជាតុលាការគំរូ។

**៨-យន្តការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ៖**

គិតគូររៀបចំអោយបានឆាប់នូវយន្តការមួយសមស្រប ក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

ជាបន្ទាប់ ចូលមកដល់របៀបវារៈសំណួរ ចម្លើយ និងការផ្តល់យោបល់ ឬសំណូមពរផ្សេងៗរបស់អង្គសិក្ខាសាលាទាំងមូល។

លោក **ស៊ុន ម៉ុនធឿន** បានចោទជាសំណួរថា ចំពោះយន្តការការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តើស្ថាប័នណាខ្លះអាចដោះស្រាយបាន? ហើយបទល្មើសណាខ្លះដែលអាចដោះស្រាយក្រៅប្រព័ន្ធតុលាការនេះបានដែរ?

ទាក់ទងទៅនឹងសំណួរនេះ ឯកឧត្តមអភិបាលរងខេត្តមណ្ឌលគីរីបានមានប្រសាសន៍ថា មន្ត្រីរាជការថ្នាក់ខេត្ត មានការយល់ដឹងអំពីច្បាប់ស្តួចស្តើងណាស់ ហើយឯកឧត្តមបានបន្ថែមទៀតថា ប្រជាពលរដ្ឋរស់នៅក្នុងខេត្តមណ្ឌលគីរី គឺមានចំនួនតិច ដូច្នេះរឿងវិវាទក៏នៅមានកំរិតតិចដែរ។

ឯកឧត្តម **ម៉ែន ម៉ុនឈា** បានចូលរួមផ្តល់ជាមតិយោបល់ថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងសុរិយោដី។ ក្រុមប្រឹក្សាឃុំសង្កាត់ក៏មានអនុក្រឹត្យបែងចែកអំណាចយ៉ាងច្បាស់លាស់អំពីតួនាទីរបស់ពួកគាត់ ហើយការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺវាអាស្រ័យទៅលើរឿងវិវាទនោះដែរ ឬក៏ទៅលើការងារ ឬក៏រឿងវិវាទជាក់ស្តែង។ ជាមួយគ្នានោះដែរ ឯកឧត្តមបានលើកយកឧទាហរណ៍មួយក្នុងករណីទាក់ទងនឹងវិវាទការងារ ឯកឧត្តមបានមានប្រសាសន៍ថា ជាក់ស្តែងក្នុងការដោះស្រាយវិវាទការងារនេះ ដំបូងគឺក្រសួងមានតួនាទីជាអ្នកផ្សះផ្សា និងសម្របសម្រួលជាមួយសហជីពកម្មករ និយោជិត និងក្រុមហ៊ុន។ ក្នុងករណីវិវាទនោះ មិនអាចឈានទៅដល់ការសះជានឹងគ្នាទេ ហើយភាគីទាំងពីរឯកភាពអោយយកវិវាទនោះជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយបន្តនោះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើលិខិតបញ្ជូនសំណុំរឿងនោះមកក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។

ឯកឧត្តម **ផៃ សុខខេង** ប្រធានក្រុមគម្រោងកំណែទម្រង់យុត្តិធម៌ មានប្រសាសន៍ថា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយរឿងទំនៀមទំលាប់ អាជ្ញាធរអាចដោះស្រាយត្រឹមតែសម្របសម្រួលប៉ុណ្ណោះ ចំណែករឿងព្រហ្មទណ្ឌ គឺមានតែតុលាការទេដែលជាអ្នកដោះស្រាយ។ ឯកឧត្តមមានប្រសាសន៍បន្ថែមទៀតថា យើងត្រូវធ្វើការសម្រួលទៅលើផ្នែកពាណិជ្ជកម្ម(មជ្ឈត្តកម្មពាណិជ្ជកម្ម) ចំពោះបញ្ហាដីធ្លីដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ គឺគណៈកម្មការសុរិយោដីថ្នាក់ជាតិជាអ្នកដោះស្រាយ ចំណែកបញ្ហាដីធ្លីដែលមានប័ណ្ណកម្មសិទ្ធិរួចហើយនោះ គឺជាតួនាទីរបស់តុលាការជាអ្នកដោះស្រាយ។ ចំពោះមេឃុំ ចៅសង្កាត់ និងអភិបាលស្រុកមានតួនាទីត្រឹមតែជាអ្នកសម្របសម្រួលតែប៉ុណ្ណោះ ប៉ុន្តែមិនមែនជាផ្លូវការនោះទេ។

**សំណួរ** ៖ មានប្រកាសអន្តរក្រសួង ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃបានចែងថា ចំពោះការដោះស្រាយទំនាស់ដីធ្លីទាំងឡាយណា ដែលមិនទាន់ចុះបញ្ជីជាផ្លូវការមិនមែនជាសមត្ថកិច្ចរបស់តុលាការខេត្តនោះទេ វាជាសមត្ថកិច្ចរបស់គណៈកម្មការសុរីយោដីខេត្ត តែការសង្កេតឃើញជាក់ស្តែងបច្ចុប្បន្ននេះ តុលការខេត្តក៏ដូចជាព្រះរាជអាជ្ញា នៅតែបន្តការដោះស្រាយជាបន្តបន្ទាប់ផ្ទុយពីប្រកាសអន្តរក្រសួងដែលនាំឱ្យការដោះស្រាយមានភាពអនាធិបតេយ្យ។ តើការប្រកាស របស់អន្តរក្រសួង ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃដែលបានដាក់ចេញមក ដើម្បីឱ្យតុលាការអនុវត្ត ឬក៏គ្រាន់តែចេញមក ឱ្យតែឃើញឱ្យតែ ៗ រីឯការអនុវត្តវិញថ្នាក់ក្រោមមិនអនុវត្ត ហើយតើក្រសួងយុត្តិធម៌បានតាមដានត្រួតពិនត្យលើការអនុវត្តច្បាប់នេះដែរឬទេ?

ឯកឧត្តម **សួង លាងហៃ** បានមានប្រសាសន៍ថា បញ្ហាកម្មសិទ្ធិដីធ្លីវាទាក់ទងទៅនឹងគណៈកម្មការសុរិយោដី ហើយសព្វថ្ងៃនេះក្រសួងនគរូបនីយកម្មដែនដី និងសំណង់បានខិតខំប្រឹងប្រែងខ្លាំងណាស់ក្នុងការងារដោះស្រាយ និងធ្វើប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋនេះ។

**សំណួរ** ៖ តើព្រះរាជអាជ្ញាអមតុលាការអាចចេញដីការកោះហៅ ឬចាប់ខ្លួនបុគ្គលណាម្នាក់បានដែរឬទេ នៅពេលដែលគ្មានពាក្យបណ្តឹងចោទប្រកាន់ទៅលើបុគ្គលនោះ?

ឯកឧត្តម **ម៉ែន ម៉ុនឈា** បានមានប្រសាសន៍ថា ខាងក្រសួងយុត្តិធម៌កំពុងតែអនុវត្តលើបញ្ហាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចតុលាការនេះ។ ឯកឧត្តមបានបញ្ជាក់ផងដែរចំពោះតួនាទីរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺមានតួនាទីជាអ្នកដាក់ពិន័យលើចៅក្រម ដែលប្រព្រឹត្តខុស ចំណែកព្រះរាជអាជ្ញា មានសិទ្ធិការពារផលប្រយោជន៍សាធារណៈ ទោះបីគ្មានការប្តឹងផ្តល់ក៏ដោយ ព្រោះវាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា។

នៅទីបញ្ចប់ឯកឧត្តម **សួង លាងហៃ** បានធ្វើការបូកសរុបលទ្ធផលនៃការពិភាក្សា និងបានសន្យាថា នឹងស្រង់នូវគំនិតយោបល់ល្អៗរបស់អង្គសិក្ខាសាលា ទៅធ្វើការពិចារណាក្នុងការអនុវត្តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការជាបន្តឱ្យបានកាន់តែប្រសើរថែមទៀត។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ២០០៧*

**បានឃើញ និងឯកភាព**

គណៈធិបតីនៃអង្គសិក្ខាសាលា　　　　　　　　　　អ្នកធ្វើរបាយការណ៍

សួង លាងហៃ　　　　　　　　　　សេង វ៉ាន់ដា　　ស៊ុសិរីវុធ